លេខាធិការដ្ឋាន គ.ជ.អ.ប
ការពិពណ៌នាការងារ
( Job Description - JD )

| | |
|---|---|
| **គម្រោង** | គម្រោងសមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងប្រព័ន្ធរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ |
| **មុខតំណែង** | **អ្នកបើកបរ (២ មុខតំណែង)** |
| **ទីកន្លែងបំពេញការងារ** | លេខាធិការដ្ឋាន គ.ជ.អ.ប |
| **រយៈពេល** | មួយឆ្នាំ (អាចបន្តផ្អែកលើលទ្ធផលនៃការវាយតម្លៃប្រចាំឆ្នាំ) |

## ១. សាវតា

គម្រោងសមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងប្រព័ន្ធរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ គឺជាគម្រោងរបស់រដ្ឋាភិបាលដែលទទួលបានការគាំទ្រការថវិកាពីមូលនិធិបរធនបាលកិច្ច (Trust Fund) នៃធនាគារពិភពលោក ដើម្បីគាំទ្រការអនុវត្តផែនការអនុវត្តគណនេយ្យភាពសង្គមដំណាក់កាលទី២ (២០១៩-២០២៣)។ គម្រោងមានគោលបំណងធ្វើឱ្យប្រសើរឡើងនូវការបំពេញការងាររបស់អ្នកផ្តល់សេវាសាធារណៈតាមរយៈការរៀបចំ និងការអភិវឌ្ឍស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ការធ្វើឲ្យប្រសើរឡើងនូវតម្លាភាព ពង្រឹងការចូលរួមរបស់ពលរដ្ឋ និងសកម្មភាពឆ្លើយតបនានា។ គោលបំណងនេះនឹងសម្រេចបានតាមរយៈ ១) តម្លាភាព ភាពងាយទទួលបានព័ត៌មាននានា និងព័ត៌មានថវិកា ២)ការត្រួតពិនិត្យតាមដានដោយប្រជាពលរដ្ឋ ៣)ការអនុវត្ត ផែនការសកម្មភាពរួមស្តីពីការងារគណនេយ្យភាពសង្គម (ផ.ស.រ.គ) ៤)ការបណ្តុះបណ្តាល និងអភិវឌ្ឍសមត្ថភាព និង៥)ការសម្របសម្រួលនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ និងការគាំទ្រភាពជាដៃគូ។ លេខាធិការដ្ឋាន គ.ជ.អ.ប. គឺជាភ្នាក់ងារអនុវត្តរបស់គម្រោងដែលទទួលខុសត្រូវទៅលើការគ្រប់គ្រង សម្របសម្រួល និងអនុវត្តគម្រោង ព្រមទាំងការងារលទ្ធកម្ម ការទំលាក់ថវិកា ការគ្រប់គ្រងហិរញ្ញវត្ថុ និងគ្រប់គ្រងហានិភ័យសង្គម និងបរិស្ថាន។

## ២. តួនាទី និងភារកិច្ច

### ២.១. តួនាទី និងភារកិច្ចទូទៅ

អ្នកបើកបរត្រូវទទួលខុសត្រូវចំពោះរថយន្តរបស់គម្រោង ដោយត្រួតពិនិត្យជាប្រចាំ មើលការថែទាំ និងជួសជុលជាដើម។

### ២.២. ភារកិច្ចជាក់លាក់

ភារកិច្ចសំខាន់ៗរបស់អ្នកបើកបរមានដូចខាងក្រោម៖

- គោរពច្បាប់ចរាចរណ៍

- គោរពនូវគោលការណ៍សុវត្ថិភាពនៃការបើកបរ ដូចជាការបំពាក់ខ្សែក្រវ៉ាត់សុវត្ថិភាព
- រក្សានូវអនាម័យ និងភាពស្អាតរបស់រថយន្ត
- រក្សានូវឧបករណ៍ កង់បម្រុង និងឧបករណ៍សង្គ្រោះបឋមឱ្យមាននៅក្នុងរថយន្ត
- មិនជក់បារី និងហាមអ្នកធ្វើដំណើរមិនឱ្យជក់បារី
- ចាក់ប្រេងបន្ថែមឱ្យពេញបន្ទាប់ពីបញ្ចប់បេសកម្មនៅតាមខេត្តរួចរាល់
- កត់ត្រា និងធ្វើបច្ចុប្បន្នភាពលើសៀវភៅប្រើប្រាស់រថយន្ត
- មិនត្រូវផ្តួចផ្តើមគំនិតពិភាក្សាជាមួយអ្នកធ្វើដំណើរក្នុងពេលធ្វើដំណើរឡើយ
- មិនអនុញ្ញាតឱ្យទទួលទានគ្រឿងស្រវឹងក្នុងពេលបើកបរ
- រាយការណ៍អំពីការជួសជុល និងការថែរក្សារថយន្តជូនថ្នាក់ដឹកនាំ
- ជួយរៀបចំដាក់ឥវ៉ាន់ និងសម្ភារៈនានាសំដៅបម្រើដល់សកម្មភាពនានារបស់គម្រោង
- បំពេញការងារផ្សេងៗទៀតតាមការស្នើសុំរបស់ប្រធានគម្រោង

## ៣. ការទទួលខុសត្រូវ និងខ្សែគណនេយ្យភាព

អ្នកបើកបររបស់គម្រោងសមាហរណកម្មគណនេយ្យភាពសង្គមទៅក្នុងប្រព័ន្ធរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ ប្រចាំនៅលេខាធិការដ្ឋានគ.ជ.អ.ប ត្រូវចុះកិច្ចសន្យាបំពេញការងារជាមួយ និងស្ថិតនៅក្រោមការទទួលខុសត្រូវរួមរបស់ប្រធានគ្រប់គ្រងគម្រោងសមាហរណកម្មគណនេយ្យភាពសង្គម ទៅក្នុងប្រព័ន្ធរដ្ឋបាលថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ នៃលេខាធិការដ្ឋាន គ.ជ.អ.ប ។

## ៤. ចំណេះដឹង និងបទពិសោធន៍

បេក្ខជនត្រូវមានលក្ខណៈសម្បត្តិដូចខាងក្រោមៈ

- កម្រិតវប្បធម៌ៈ មានសញ្ញាបត្រមធ្យមសិក្សាទុតិយភូមិ (បាក់ឌុប) ឬសញ្ញាបត្រមានតម្លៃស្មើ
- ប័ណ្ណបើកបរមានសុពលភាព
- មានបទពិសោធន៍យ៉ាងតិច ៣ឆ្នាំ
- ចេះច្បាប់ចរាចរណ៍
- មានឆន្ទៈក្នុងការបំពេញការងារ
- មានអត្តចរិត្តល្អ រួសរាយរាក់ទាក់
- មានទំនួលខុសត្រូវចំពោះតួនាទី និងភារកិច្ចរបស់ខ្លួន

## ៥. ទីកន្លែងដាក់ពាក្យ និងកាលបរិច្ឆេទ

បេក្ខជនដែលមានចំណាប់អារម្មណ៍ និងបំពេញល័ក្ខខ័ណ្ឌដូចរៀបរាប់ខាងលើ សូមបំពេញបែបបទបំពេញការងារដែលមានភ្ជាប់មកជាមួយសេចក្តីប្រកាសនេះ និងផ្ញើមកលេខាធិការដ្ឋាន គ.ជ.អ.ប ដែលមានអាសយដ្ឋាននៅក្នុងបរិវេណក្រសួងមហាផ្ទៃ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជ

ជានីភ្នំពេញ អាគារ T ជាន់ផ្ទាល់ដី បន្ទប់អង្គភាពត្រួតពិនិត្យ វាយតម្លៃ និងព័ត៌មាន (MEID) ឬអាចផ្ញើមកសារអេឡិចត្រូនិច info@ncdd.gov.kh។ **ឈប់ទទួលពាក្យនៅថ្ងៃទី២០ ខែវិច្ឆិកា ឆ្នាំ២០២០ វេលាម៉ោង៥:០០ រសៀល។**

**បញ្ជាក់ ៖ មុខតំណែងនេះជាប្រភេទកិច្ចសន្យាការងារ ដូច្នេះបេក្ខជនដែលនឹងត្រូវជ្រើសរើសឱ្យបំពេញការងារ ត្រូវតែមិនមែនជាបុគ្គលិករាជការស៊ីវិល។ ក្នុងករណីដែលបេក្ខជនជាបុគ្គលិករាជការស៊ីវិល បេក្ខជននោះត្រូវដាក់ពាក្យសុំស្ថិតនៅក្នុងភាពទំនេរគ្មានប្រាក់បៀវត្សរ៍ ក្នុងរយៈពេលនៃការបំពេញការងារជាមួយគម្រោង។**